# ការយកសំណាកគ្រាប់ស្រូវ អង្ករ
## Grain Sampling

**១.តើអ្វីទៅជាការយកសំណាក?** What is grain sampling?

ការយកសំណាក គឺជាដំណើរការជ្រើសរើសគ្រាប់ធញ្ញជាតិមួយចំណែកតូចពីបរិមាណដ៏ច្រើន ពីវាលស្រែ ពីគំនរ ឬពីក្នុងបាវ ។ គោលបំណងនៃការយកសំណាកត្រឹមត្រូវ គឺជាការប្រមូលនូវ " **សំណាកតំណាង**" មានន័យថា ភាគរយនៃគ្រាប់ធញ្ញជាតិដែលមានលក្ខណៈខុសគ្នា(ឧ.សំណើមគ្រាប់)នៅក្នុងសំណាក ដូចគ្នាទៅនឹងឡូត៍ឬគំនរដែលសំណាកត្រូវបានយកចេញ ។

**២.ហេតុអ្វីបានជាការយកសំណាកត្រឹមត្រូវ មានសារៈសំខាន់?** Why is proper grain sampling important?

ស្រូវ គឺជាសារធាតុវិសភាគ និងដោយសារតែទំហំវាលស្រែតូច និងការប្រើប្រាស់ប្រភេទខុសៗគ្នាជាច្រើនក្នុងប្រទេសជាច្រើននៅអាស៊ី ទើបធ្វើអោយស្រូវឬអង្ករដែលរក្សានៅក្នុងឡូត៍ គំនរ ឬឃ្លាំងអាចលាយឡំគ្នាយ៉ាងច្រើន ។ សូម្បីតែក្នុងវាលស្រែតែមួយអត្រាសំណើមក៏អាចខុសគ្នាដែរនៅក្នុងកន្លែងតែមួយ ។ ដូច្នេះវិធីសាស្ត្រយកសំណាកអោយបានត្រឹមត្រូវ គឺជាការសំខាន់ណាស់ ដើម្បីទទួលបានសំណាកតំណាងទាំងមូល ។

**៣.របៀបយកសំណាកអោយបានត្រឹមត្រូវ?** How to sample properly?

**៣.១ សំណាកនៅវាលស្រែ** (Field sample)

ដើម្បីទទួលបានសំណាកតំណាងនៅវាលស្រែមុនពេលច្រូតកាត់ជាការលំបាក :

-ពេលដែលជួរខាងក្រៅខុសពីធម្មតា ចូរដើរកាត់វាលស្រែតាមធម្មតា

-ដៃបេះ និងបកសំបកចេញពីគ្រាប់ស្រូវ ពី ៤-៥ គុម្ព ហើយច្របល់សំណាកចូលគ្នា

-មើលយ៉ាងតិចណាស់ ៣ដង ដើម្បីរកតំលៃមធ្យម ។

**៣.២ សំណាកគ្រាប់ផ្ទុកក្នុងឃ្លាំង** (Grain load sample)

ពេលដែលយកសំណាកគ្រាប់ស្រូវផ្ទុកក្នុងឃ្លាំងច្រើនកន្លែង (ជៀសវាងយក កណ្តាល និងកាច់ជ្រុង) ឬដោយចូលចិត្ត យកសំណាកគ្រាប់ដែលហូរចុះមកពីគំនរក្នុងអំឡុងពេលផ្ទុក ឬផ្ទេរ :

-ដាក់កំប៉ុងឆ្លងកាត់លំហូរគ្រាប់ស្រូវក្នុងចន្លោះមួយជាក់លាក់ និងប្រមូលគ្រាប់ចូលក្នុងធុង

-បន្ទាប់ពីការផ្ទុកនិងការផ្ទេរត្រូវបញ្ចប់ត្រូវច្របល់គ្រាប់ក្នុងធុង ក្រោយមកចាក់សំណាកចេញ ។

**៣.៣ សំណាកស្រូវក្នុងជង្រុក** (Bin sample)

ពេលយកសំណាកក្នុងជង្រុក

ប្រដាប់ស្ទង់ដើម្បីប្រមូលសំណាកពីជំរៅផ្សេងៗគ្នានឹងផ្តល់អោយនូវសំណាកតំណាងមួយ ជាក់លាក់ :

-សំណាកពីជង្រុកផ្តល់ទៅជាផ្នែកមួយតំណាងអោយទំហំស្រូវទាំងមូល

-ចូរកុំច្របល់សំណាកចូលគ្នា និងធ្វើតេស្តដាច់ដោយឡែកពីគ្នា ។ ចូរគិតថាលក្ខណៈសំណាកនៅទីតាំងខុស១គ្នានឹងជួយក្នុងការធ្វើការសំរេចចិត្តបានល្អប្រសើរ ។



**៣.៤ សំណាកនៅក្នុងបាវ** (Sack sample)

ប្រសិនបើគ្រាប់ពូជត្រូវបានគេធ្វើតេស្តពីឡូត៍ដែលមានច្រើនបាវ សំណាកគួរតែត្រូវបានយកចេញពីបាវមួយចំនួន ។ តាមការពិសោធន៍ដ៏ត្រឹមត្រូវក្នុងការកំណត់ចំនួនបាវដើម្បីយកសំណាកគឺត្រូវតែយកសំណាកពីចំនួនបាវដែលតំណាងឬសការេនៃទំហំឡូត៍ទាំងមូល ។ ឧទាហរណ៍ : ប្រសិនបើ ឡូត៍មាន ៩បាវ ពេលនោះសំណាកត្រូវយកយ៉ាងហោចណាស់ ៣បាវ បើឡូត៍មាន ១០០បាវ ពេលនោះ សំណាកត្រូវយកយ៉ាងហោចណាស់ ១០បាវ ។

**៣.៥ ការធ្វើតេស្តសំណាក** Treatment of samples

ត្រូវធ្វើតេស្តសំណាកដែលយកមកអោយបានឆាប់រហ័សព្រោះការផ្លាស់ប្តូរសំណើម និងគុណភាពកើតឡើងរាល់ពេល :

-ត្រូវបិទគំរបកំប៉ុងដាក់សំណាក ឬបិទមាត់ថង់ប្លាស្ទិចភ្លាមបន្ទាប់ពីយកសំណាករួច ដើម្បីរក្សាអត្រាសំណើមពេលយក។

-ប្រសិនបើស្តុកទុកបណ្តុះអាសន្នត្រូវទុកវានៅក្នុងទូទឹកកក ឬបន្ទប់ត្រជាក់ ។

-ត្រូវដាក់ផ្លាកសញ្ញាសមរម្យដែលប្រើប៊ិចមិនរលុប សសេរ ឬបិទ នៅលើកំប៉ុងដាក់សំណាក ។

នៅពេលនាំសំណាក ពូជស្រូវទៅក្រៅប្រទេសត្រូវពិនិត្យបទដ្ឋានពូជស្រូវក្នុងស្រុកដោយឡែកមួយផ្សេងទៀត ។